ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ

លេខ:.................អសជ/.....

# របាយការណ៍សង្ខេបនៃ
# របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការ
# ស្តីពី
# ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅខេត្តកោះកុង
# សម្រាប់ការិយបរិច្ឆេទ២០២៥ និងឆ្នាំពាក់ព័ន្ធ

**សេចក្តីសង្ខេប**

អនុលោមតាមមាត្រា២ មាត្រា៣ និងមាត្រា៩ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើសវនកម្មលើបណ្តាក្រសួង ស្ថាប័ន និងរាជធានី ខេត្ត។ អាជ្ញាធរសវនកម្មជាតិបានជ្រើសរើសប្រធានបទស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅខេត្តកោះកុង សម្រាប់ធ្វើសវនកម្មលើកិច្ចប្រតិបត្តិការសម្រាប់ការិយបរិច្ឆេទ២០២៥ និងឆ្នាំពាក់ព័ន្ធដោយគ្របដណ្តប់លើរដ្ឋបាលក្រុងខេមរភូមិន្ទ និងរដ្ឋបាលស្រុកមណ្ឌលសីមា

បច្ចុប្បន្ននេះ ខេត្តកោះកុងបានស្នើសុំដីសម្រាប់បង្កើតទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនចំនួនមួយ ដែលស្ថិតនៅក្នុងក្រុង-ស្រុក របស់ខ្លួន ក្នុងនោះមាន៖

- ទីតាំងដីចាក់សំរាម មានទំហំ៥០០ ៨០៥ម$^2$ ភូមិទួលគគីរលើ ឃុំទួលគគីរ ស្រុកមណ្ឌលសីមា (ទីតាំងដីចាក់សំរាមសម្រាប់ប្រើរួមគ្នារវាងក្រុងខេមរភូមិន្ទ និងស្រុកមណ្ឌលសីមា)
- ទីតាំងដីចាក់សំរាម មានទំហំ**៥២ហ.ត** ស្ថិតនៅភូមិព្រែកអង្កុញ ឃុំត្រពាំងរូង ស្រុកកោះកុង
- ទីតាំងដីចាក់សំរាម មានទំហំ**៦៧ហ.ត** ស្ថិតនៅភូមិអន្លង់វ៉ាក់ ឃុំតាតៃក្រោម ស្រុកកោះកុង
- ទីតាំងដីចាក់សំរាម មានទំហំ**៨២,៥៨ហ.ត** ស្ថិតនៅភូមិជ្រោយប្រស់ ឃុំជ្រោយប្រស់ ស្រុកកោះកុង
- ទីតាំងដីចាក់សំរាម មានទំហំ**១៥០ហ.ត** (គ្រោងទីលានទុកដាក់សំរាមស្តង់ដា) ស្ថិតនៅភូមិបានទៀត ឃុំដងពែង ស្រុកស្រែអំបិល
- ទីតាំងដីចាក់សំរាម មានទំហំ**៤៦ ៨៩៨ម$^2$** ស្ថិតនៅភូមិជីមាល ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ
- ទីតាំងដីចាក់សំរាម មានទំហំ**៤០ហ.ត** ស្ថិតនៅភូមិស្រែថ្ម ឃុំថ្មស ស្រុកបូទុមសាគរ
- ទីតាំងដីចាក់សំរាម មានទំហំ**៥៥១ ០២៣ម$^2$** ស្ថិតនៅភូមិព្រែកខ្សាច់ ឃុំព្រែកខ្សាច់ ស្រុកគិរីសាគរ
- ទីតាំងដីចាក់សំរាម មានទំហំ**២៤៣ ០៩៩**ម$^2$ ស្ថិតនៅភូមិត្រពាំងឈើត្រាវ ឃុំឫស្សីជ្រុំ ស្រុកថ្មបាំង
- ទីតាំងដីចាក់សំរាម មានទំហំ**៣០០ ៤៨១**ម$^2$ ស្ថិតនៅភូមិស្ពានក្តារ ឃុំតាទៃលើ ស្រុកថ្មបាំង
- ទីតាំងដីចាក់សំរាម មានទំហំ**២៥០ ០០០**ម$^2$ ស្ថិតនៅភូមិជំនាប់ ឃុំជំនាប់ ស្រុកថ្មបាំង

- ទីតាំងដីចាក់សំរាម មានទំហំ**២០០ ០០០**ម$^២$ ស្ថិតនៅភូមិសំរោង ឃុំប្រឡាយ ស្រុកថ្មបាំង
- ទីតាំងដីចាក់សំរាម មានទំហំ**២១០ ០០០**ម$^២$ ស្ថិតនៅភូមិព្រែកស្វាយ ឃុំថ្មដូនពៅ ស្រុកថ្មបាំង
- ទីតាំងដីចាក់សំរាម មានទំហំ**២០១ ១៤៨**ម$^២$ ស្ថិតនៅភូមិជាំស្លា ឃុំជីផាត ស្រុកថ្មបាំង

គោលបំណងនៃការធ្វើសវនកម្ម ដើម្បីវាយតម្លៃថាតើ ខេត្តកោះកុងមានទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនរបស់ខ្លួនគ្រប់ចំនួន ដើម្បីធានាបាននូវការគ្រប់គ្រងកាកសំណល់នៅតាមទីប្រជុំជននៃរដ្ឋបាលក្រុង-ស្រុកនីមួយៗ ប្រកបដោយសុវត្ថិភាពបរិស្ថាននិងចីរភាព ព្រមទាំងធានាបាននូវការចូលរួមចំណែកក្នុងការអនុវត្តនៃក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០ និងរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តឆ្នាំ២០២៣ : ជំរុញការស្តារសង្គមសេដ្ឋកិច្ចឡើងវិញពីផលប៉ះពាល់នៃជំងឺកូវីដ១៩ និងការអនុវត្តពេញលេញរបៀបវារៈឆ្នាំ២០៣០។ ជាពិសេស ដើម្បីចូលរួមចំណែកនៃការអនុវត្តគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មលើកិច្ចប្រតិបត្តិការស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅខេត្តកោះកុង ដោយគ្របដណ្តប់លើរដ្ឋបាលក្រុងខេមរភូមិន្ទ និងរដ្ឋបាលមណ្ឌលសីមាសម្រាប់ការិយបរិច្ឆេទ២០២៥ និងឆ្នាំពាក់ព័ន្ធ។ ជាលទ្ធផលបានបង្ហាញថា រដ្ឋបាលខេត្តកោះកុង បានប្រឈមនឹងកង្វះទីលានទុកដាក់សំរាម សំណល់រឹងនៅតាមបណ្តារដ្ឋបាលក្រុង-ស្រុក កង្វះខាតនូវការយល់ដឹងស្តីពីការញែក វេចខ្ចប់ និងទុកដាក់សំរាម សំណល់រឹងទីប្រជុំជន កង្វះខាតទាំងចំនួន និងប្រភេទនៃរថយន្តសម្រាប់ធ្វើសេវាកម្មដឹកជញ្ជូនកាកសំណល់ទៅកាន់ទីលានទុកដាក់សំរាម ប្រកបដោយស្តង់ដាសុវត្ថិភាពនិងអនាម័យ។

កត្តានេះ នាំឱ្យប៉ះពាល់ដល់សុវត្ថិភាពបរិស្ថាន សុខភាពសាធារណៈ និងសោភ័ណភាពទីក្រុង ហើយនាំឱ្យជះឥទ្ធិពលជាអវិជ្ជមានដល់សេដ្ឋកិច្ច ពីព្រោះថាសំរាមក៏ជាប្រភពនៃចំណូលផងដែរ ជាអាទិ៍ វាជាប្រភពនៃការកែច្នៃបង្កើតថាមពលអគ្គិសនី និងក៏ជាប្រភពនៃការកែច្នៃជីកំប៉ុស្តិ៍ទៀតផង។

តាមលទ្ធផលដែលបានបង្ហាញជូនខាងលើនេះ អាជ្ញាធរសវនកម្មជាតិសូមផ្តល់អនុសាសន៍ជូនរដ្ឋបាលខេត្តកោះកុងក៏ដូចជារដ្ឋបាលក្រុង-ស្រុករបស់ខ្លួន ដូចតទៅ៖

(១) រដ្ឋបាលខេត្តកោះកុងគួររួសរាន់ស្នើសុំបង្កើតទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនស្តង់ដាលើទីតាំងដែលរាជរដ្ឋាភិបាលកម្ពុជាបានឯកភាព ទៅក្រសួងស្ថាប័នមានសមត្ថកិច្ចស្របតាមប្លង់គោលរបស់រដ្ឋបាលខេត្តកោះកុង និងប្លង់គោលរបស់រដ្ឋបាលក្រុង-ស្រុកនីមួយៗ និងស្របតាមលក្ខខណ្ឌដែលក្រសួងបរិស្ថានបានកំណត់ និងសម្របសម្រួល។

(២) រដ្ឋបាលក្រុង-ស្រុកនៃខេត្តកោះកុង គួរបង្កើននូវការផ្សព្វផ្សាយ និងណែនាំដល់ប្រជាពលរដ្ឋ និងសាធារណជន ស្តីពីការញែក ការវេចខ្ចប់ និងការទុកដាក់សំរាម ឱ្យបានត្រឹមត្រូវ ព្រមទាំងគួរស្វះស្វែងរកធុងសំរាមឱ្យបានគ្រប់ប្រភេទ ដើម្បីឱ្យប្រជាពលរដ្ឋ និងសាធារណជនទុកដាក់សំរាម សំណល់រឹងឱ្យបានត្រឹមត្រូវ និងគួររិះរកមធ្យោបាយ ដើម្បីឱ្យក្រុមហ៊ុនដែលបានចុះកិច្ចសន្យាស្តីពីការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន មានរថយន្តដឹកជញ្ជូនសំរាមទៅតាមប្រភេទសំរាមនីមួយៗ ដែលសាធារណជនបានញែក បានវេចខ្ចប់ និងបានទុកដាក់នៅតាមបណ្តាប្រភេទធុងសំរាមនីមួយៗតាមគោលការណ៍ដែលក្រសួងបរិស្ថានបានកំណត់។

(៣) រដ្ឋបាលខេត្តកោះកុងគួរណែនាំដល់រដ្ឋបាលក្រុង-ស្រុករបស់ខ្លួន ឱ្យបង្កើនការទទួលខុសត្រូវលើការគ្រប់គ្រងសេវាសម្អាត ប្រមូល និងដឹកជញ្ជូន ការកែច្នៃ ការទាញយកធនធាន និងការធ្វើប្រព្រឹត្តកម្មពីសំណល់រឹង ព្រមទាំងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាបានប្រសិទ្ធភាពលើកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងកិច្ចគាំពារសុខភាពសាធារណៈ ប្រកបដោយសុវត្ថិភាពបរិស្ថាន។

(៤) រដ្ឋបាលខេត្តកោះកុងគួរបន្តជំរុញឱ្យមន្ទីរបរិស្ថាន និងរដ្ឋបាលក្រុង-ស្រុកនីមួយៗ បង្កើននូវការអប់រំ និងការណែនាំប្រជាពលរដ្ឋ និងសាធារណជនដែលបានរស់នៅក្នុងភូមិសាស្ត្ររបស់ខ្លួន យល់ដឹងឱ្យកាន់ច្បាស់អំពីសារប្រយោជន៍នៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងការចូលរួមក្នុងការបង់កម្រៃសេវាសំរាមរបស់ខ្លួន ឱ្យបានគ្រប់ចំនួន។

**មតិរបស់រដ្ឋបាលខេត្តកោះកុង**

រដ្ឋបាលខេត្តកោះកុងសូមឯកភាពតាមការសង្កេត និងអនុវត្តតាមអនុសាសន៍សវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ។